# ការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា

CCC, KSSA/ICF Meeting room

1st April 2014

ដោយ ឯ.ឧ ជាម ប៉េអា

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញនូវការប្តេជ្ញាចិត្តមុះមុត ក្នុងការងារកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន សំដៅពង្រឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការដាក់ចេញនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ ចាប់តាំងពីមានគោលនយោបាយនេះមក មានកិច្ចការជាច្រើនដែលយើងសម្រេចបាន ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាទាំង០៣លំដាប់ថ្នាក់រដ្ឋបាល គឺ ថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ព្រមទាំងបានរៀបចំជាអនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំនិង សេចក្តីណែនាំ ការបណ្តុះបណ្តាល ហើយដែលបន្តបន្ទាប់ ថ្នាក់រដ្ឋបាលទាំងនោះ នឹងទទួលនូវសមត្ថភាព ការផ្ទេរមុខងារ ថវិកា និង ធនធានមនុស្ស ដើម្បីអនុវត្តកិច្ចការសាធាណៈសំខាន់ៗ ក្នុងន័យធ្វើយ៉ាងណាឱ្យសេវា សាធារណៈទាំងនោះបានខិតជិតប្រជាពលរដ្ឋ និងផ្តល់ជូនប្រកបដោយប្រសិទ្ធភាព។

ដើម្បីដឹងថាអភិបាលកិច្ចមូលដ្ឋាន មានប្រសិទ្ធភាពយ៉ាងនោះ យើងត្រូវការឧបករណ៍ឆ្លុះបញ្ចាំងអំពី លទ្ធផលនៃកំណែទម្រង់របស់យើង ដែលក្នុងនោះយើងគិតថា **គណនេយ្យភាពសង្គម** គឺជាឧបករណ៍មួយដ៏មានសារៈសំខាន់ក្នុងការចូលរួមចំណែក ដល់ការពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ ដោយសារតែគណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើរ រវាងប្រជាពលរដ្ឋ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវាក៏ជាមធ្យោបាយមួយដែលបន្សុីគ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ច ដែលក្នុងនោះរាល់ការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រកាន់យកតាមកិច្ចដំណើរការនេះ។

កិច្ចសហការរវាងរដ្ឋបាលមូលដ្ឋាន (អ្នកផ្តល់សេវា) និងប្រជាពលរដ្ឋ (អ្នកប្រើប្រាស់សេវា) សំដៅគាំទ្រដល់អ្នកផ្តល់សេវាសាធារណៈ ឲ្យបំពេញការងាររបស់ខ្លួនបានប្រសើរជាងមុន។ បទពិសោធន៍កន្លងមកបានបង្ហាញថា ឧបករណ៍គណនេយ្យភាពសង្គមនានា (ដូចជាប័ណ្ណដាក់ពិន្ទុសហគមន៍) ជួយជំរុញឲ្យមានការគោរពគ្នា និងការចូលរួមរវាងប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋាន។

ថ្មីៗនេះ គ.ជ.អ.ប បានអនុម័តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម ដែលមានយុទ្ធសាស្ត្រចំនួនប្រាំ ដើម្បីសម្រេចបាននូវគោលបំណងរួមក្នុងការពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងពង្រឹងគណនេយ្យភាពសង្គមនៅកម្ពុជា។ យុទ្ធសាស្ត្រទាំងប្រាំនៃផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម ដើម្បីជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព មានដូចខាងក្រោម៖

១. ការលើកកម្ពស់តម្លាភាព និងភាពងាយទទួលបាននូវព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ

២. ការសម្របសម្រួលឲ្យមានការត្រួតពិនិត្យ តាមដានរបស់ប្រជាពលរដ្ឋលើសកម្មភាព និងការផ្តល់សេវាកម្មមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ

៣. ការលើកកម្ពស់សមត្ថភាពយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកា

៤. ការគាំទ្រដល់តួអង្គនានា និងការកសាងសមត្ថភាពដល់តួអង្គទាំងនោះ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានានៃគណនេយ្យភាពសង្គម
៥. ការប្រមូលមេរៀនបទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន ដើម្បីប្រែក្លាយបទពិសោធន៍ទាំងនេះដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងពង្រឹងការបំពេញការងារអង្គការសង្គមស៊ីវិលនានា។

ផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយទៅជាផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់សម្រាប់ភាគីពាក់ព័ន្ធនានា និងជាមូលដ្ឋានគ្រឹះនៃការរៀបចំផែនការសកម្មភាព និងថវិកាលម្អិត និងកម្មវិធីអន្តរាគមន៍ជាក់លាក់នានារបស់ភាគីពាក់ព័ន្ធទាំងឡាយ។ ការអនុវត្តដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រនេះ នឹងចូលរួមចំណែកយ៉ាងធំធេង ក្នុងការសម្រេចបាននូវគោលបំណងនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន កែលំអការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលនានាដោយមានការចូលរួមតាមលក្ខណៈប្រជាធិបតេយ្យ តម្លាភាព គណនេយ្យភាព ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយភាពស័ក្តិសិទ្ធិ។

តើក្រុមប្រជាពលរដ្ឋ/អង្គការសង្គមស៊ីវិល និងស្ថាប័ននិងអង្គភាពរាជរដ្ឋាភិបាល នៅមូលដ្ឋាន គួរធ្វើអ្វីខ្លះ ដើម្បីប្រែក្លាយយុទ្ធសាស្ត្រឱ្យទៅជាការអនុវត្តជាក់ស្តែង៖

**យុទ្ធសាស្ត្រទី១ ស្តីពីព័ត៌មាន** (លើកកម្ពស់តម្លាភាព និងលទ្ធភាពទទួលបានព័ត៌មានអំពីស្តង់ដារសេវា ថវិកា និងការបំពេញការងារ)៖

- **ក្រុមប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល**៖ គួរតែកសាងចំណេះដឹង និងជួយគាំទ្រឲ្យប្រជាពលរដ្ឋមានការយល់ដឹងនិងមានលទ្ធភាពទទួលបានព័ត៌មានពីរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែប្រសើរ ។
- **ស្ថាប័ននិងអង្គភាពនានារបស់រាជរដ្ឋាភិបាល** ត្រូវ៖
  - រៀបចំលិខិតបទដ្ឋាន និងកិច្ចដំណើរការស្តីពីការផ្សព្វផ្សាយព័ត៌មាន ជាសាធារណៈដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ ការិយាល័យ ជំនាញ
  - ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនានា ដើម្បីឲ្យមានការយល់ដឹង និងអនុវត្តនូវល័ក្ខខ័ណ្ឌនានាក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ
  - ជំរុញការអនុវត្ត និងត្រួតពិនិត្យការអនុវត្តនូវល័ក្ខខ័ណ្ឌនានានៃការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

**យុទ្ធសាស្ត្រទី២ ស្តីពីការតាមដានត្រួតពិនិត្យ** ៖ បង្កើត យន្តការតាមដាននិងការធ្វើរបាយការណ៍របស់ប្រជាពលរដ្ឋទៅលើសកម្មភាពនានា និងការផ្តល់សេវាកម្មនៅមូលដ្ឋាន

- **ក្រុមប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល**៖
  - រៀបចំឱ្យមានការតាមដាន ត្រួតពិនិត្យជាប្រចាំរបស់សហគមន៍លើសកម្មភាពនានា និងការផ្តល់សេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បង្កលទ្ធភាពឲ្យប្រជាពលរដ្ឋ និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ ក្រោមជាតិមានលទ្ធភាពតាមដានត្រួតពិនិត្យទៅលើការផ្តល់សេវាកម្មនៅមូលដ្ឋានរបស់មន្ទីរ ការិយាល័យជំនាញ (ដូចជាសេវាសុខភាព អប់រំ ទឹកស្អាត និងការគ្រប់គ្រងធនធានធម្មជាតិ)
- **ស្ថាប័ននិងអង្គភាពនានារបស់រាជរដ្ឋាភិបាល** ត្រូវ៖
  - រៀបចំបង្កើតនិងពង្រឹងឧបករណ៍នានាសម្រាប់ការងារត្រួតពិនិត្យតាមដានរបស់ថ្នាក់ជាតិ
  - រៀបចំ និងផ្សព្វផ្សាយជាសាធារណៈនូវស្តង់ដានៃការផ្តល់សេវាកម្ម សាធារណៈដោយមានកិច្ចសហការជាមួយប្រជាពលរដ្ឋ
  - ដាក់បញ្ចូលនូវយន្តការ និងនីតិវិធីត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋឲ្យទៅជាផ្នែកមួយនៃផែនការប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ
  - រៀបចំ និងបង្កើតនូវមុខងារ និងនីតិវិធីស្តីពីការត្រួតពិនិត្យមើលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅលើការផ្តល់សេវាកម្មនានានៅមូលដ្ឋាន

**យុទ្ធសាស្ត្រទី៣ ស្តីពីការងារថវិកា**៖ លើកកម្ពស់ការយល់ដឹង និងការស្វែងយល់របស់ប្រជាពលរដ្ឋអំពីការងារថវិកា

- **ក្រុមប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល**៖
  - អនុវត្តកម្មវិធីនានា ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការងារថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិ
  - រៀបចំ និងអនុវត្តនូវការវិភាគអំពីការងារថវិកាប្រកបដោយការចូលរួម
- **ស្ថាប័ននិងអង្គភាពនានារបស់រាជរដ្ឋាភិបាល** ត្រូវ៖
  - រៀបចំទម្រង់ឯកសារដែលមានលក្ខណៈសាមញ្ញសម្រាប់ក្រុមប្រឹក្សាក្នុងការបំពេញព័ត៌មានអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការថវិកា និងការចំណាយនានា និងដើម្បីពង្រឹងនូវភាពងាយស្រួលដល់ប្រជាពល រដ្ឋក្នុងការទទួលបានព័ត៌មានទាំងនេះ
  - រៀបចំបង្កើត និងដាក់បញ្ចូលយន្តការ និងនីតិវិធីត្រួតពិនិត្យហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋឲ្យទៅជាផ្នែកមួយនៃផែនការប្រចាំឆ្នាំរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ។

**យុទ្ធសាស្ត្រទី៤ ស្តីពីការផ្សារភ្ជាប់ទំនាក់ទំនង**៖ ជំរុញការផ្សារភ្ជាប់ទំនាក់ទំនងរវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ ព្រមទាំង កសាងសមត្ថភាពនានាដើម្បីសម្របសម្រួលទំនាក់ទំនងនេះ

- **ក្រុមប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល**៖
  - ផ្សារភ្ជាប់ទំនាក់ទំនង និងកសាងសមត្ថភាពអង្គការមិនមែនរដ្ឋាភិបាលដើម្បីគាំទ្រសកម្មភាពក្នុងយុទ្ធសាស្ត្រទាំងបីខាងលើ
- **ស្ថាប័ននិងអង្គភាពនានារបស់រាជរដ្ឋាភិបាល** ត្រូវ៖
  - អភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ មន្ត្រីសម្របសម្រួល ឬគាំទ្រការអភិវឌ្ឍន៍សហគមន៍) ដើម្បីគាំទ្រដល់ក្រុមប្រជាពលរដ្ឋនានា និងកំណត់បាននូវអង្គការមិនមែនរដ្ឋាភិបាលនានាដែលត្រូវចូលរួមក្នុងសកម្មភាពនេះ

**យុទ្ធសាស្ត្រទី៥ ស្ដីពី ការសិក្សាពីមេរៀន និងបទពិសោធន៍** ៖ ស្វែងយល់ និងប្រមូលបទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋានដើម្បីបញ្ចូលទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងលើកកម្ពស់ការអនុវត្តរបស់អង្គការសង្គមស៊ីវិល

- **ក្រុមប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល៖**
    - រៀបចំពីបែបផែននៃការសិក្សាមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យ តាមដានរបស់អង្គការសង្គមស៊ីវិល
    - សម្របសម្រួលនិងកំណត់អាទិភាពនូវកម្មវិធីត្រួតពិនិត្យតាមដានដែលមានលក្ខណៈសកម្ម
- **ស្ថាប័ននិងអង្គភាពនានារបស់រាជរដ្ឋាភិបាល** ត្រូវ៖
    - រៀបចំវេទិកានានា ដើម្បីឆ្លុះបញ្ចាំងនិងផ្តល់យោបល់ត្រឡប់ទៅលើការអនុវត្តជាក់ស្តែង ព្រមទាំងពិចារណាលើយោបល់ទាំងនេះ ដើម្បីដាក់បញ្ចូលទៅក្នុងការរៀបចំ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា។ សម្របសម្រួលនូវកម្មវិធីត្រួតពិនិត្យតាមដានដែលមានលក្ខណៈសកម្ម។

បច្ចុប្បន្ន គ.ជ.អ.ប បាននឹងកំពុងកសាងឯកសារផែនការសកម្មភាពនិងថវិកាលំអិត ដើម្បីដាក់ជូនដៃគូអភិវឌ្ឍ ពិនិត្យលទ្ធភាពជួយគាំទ្រ ទាំងផ្នែកប្រជាពលរដ្ឋនិងសង្គមស៊ីវិល ទាំងផ្នែកស្ថាប័នរាជរដ្ឋាភិបាល។